**អង្គភាពជនរងគ្រោះ**

## សារគន្លឹះសម្រាប់អ្នកដាក់ពាក្យបណ្តឹងសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីក្នុងសំណុំរឿង០០២

1. នៅថ្ងៃទី១១ ខែកញ្ញា ឆ្នាំ២០០៩, គណៈកម្មាធិការកិច្ចប្រជុំពេញអង្គនៃអ.វ.ត.ក បានសម្រេចកែប្រែពេលកំណត់ឈប់ទទួលពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីសម្រាប់សំណុំរឿងបច្ចុប្បន្ន ដែលកំពុងស្ថិតក្រោមការស៊ើបអង្កេតដោយ អ.វ.ត.ក (គឺសំណុំរឿង០០២)។ ពេលផុតកំណត់ថ្មីនេះគឺ ១៥ ថ្ងៃបន្ទាប់ពីការជូនដំណឹងអំពីការបញ្ចប់ដំណើរការស៊ើបអង្កេតចំនួន ។ **បច្ចុប្បន្ននេះ គណៈកម្មាធិការកិច្ចប្រជុំពេញអង្គរំពឹងថា ដំណើរការស៊ើបអង្កេតនឹងបញ្ចប់នៅចុងឆ្នាំ២០០៩ នេះ។**

2. ពាក្យស្នើសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីណាដែលបានដាក់ក្រោយពេលផុតកំណត់នេះនឹងមិនត្រូវបានពិចារណាដោយចៅក្រមនៃអង្គជំនុំជម្រះសាលាដំបូងឡើយ។

3. នេះមានន័យថា អ្នកដែលចង់ក្លាយខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីក្នុងសំណុំរឿង០០២ គួរដាក់ពាក្យស្នើសុំទៅអង្គភាពជនរងគ្រោះ **ឲ្យបានលឿនបំផុត តាមដែលអាចធ្វើបាន** ។ ធ្វើយ៉ាងនេះគឺ ដើម្បីឱ្យអង្គភាពជនរងគ្រោះ និងការិយាល័យសហចៅក្រមស៊ើបអង្កេតអាចយកចិត្តទុកដាក់ច្រើនបំផុតលើពាក្យស្នើសុំរបស់លោកអ្នក និងអាចប្រើប្រាស់ពាក្យសុំនោះតាមដំណើរការនៃនីតិវិធី ។ នេះក៏ជួយផ្តល់ពេលបន្ថែមទៀតសម្រាប់ការរកព័ត៌មានលម្អិតបន្ថែមពីអ្នកដាក់ពាក្យស្នើសុំ ប្រសិនបើមានការចាំបាច់។

4. សំណុំរឿងដែលដើមបណ្តឹងរដ្ឋប្បវេណីអាចចូលរួមនេះ (គឺសំណុំរឿង០០២) ពាក់ព័ន្ធនឹងការចោទប្រកាន់លើ **នួន ជា, អៀង សារី, អៀង ធីរិទ្ធ** និង **ខៀវ សំផន** ។ បុគ្គលទាំងនេះគឺជាអតីតមេដឹកនាំជាន់ខ្ពស់នៃរបបខ្មែរក្រហម។ ពួកគេ ត្រូវបានចោទពីបទឧក្រិដ្ឋជាតិ និងអន្តរជាតិធ្ងន់ធ្ងរ ដែលជាលទ្ធផលនៃការទទួលខុសត្រូវរបស់ពួកគេ ចំពោះការបង្កើតគោលនយោបាយ និងសកម្មភាពនានាក្នុងរបបខ្មែរក្រហម។

5. មានតែពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីដែលមានលក្ខណៈពេញលេញ និងពាក់ព័ន្ធនឹងការស៊ើបអង្កេតបច្ចុប្បន្នប៉ុណ្ណោះ ដែលនឹងត្រូវទទួលយកដោយសហចៅក្រមស៊ើបអង្កេត។ ព័ត៌មានចាំបាច់ដែលត្រូវបំពេញរួមមាន៖
    - ឈ្មោះជនរងគ្រោះម្នាក់ ឬច្រើននាក់ និងឈ្មោះអ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី។
    - អាសយដ្ឋាននៅកម្ពុជារបស់អ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី។
    - ហត្ថលេខា ឬស្នាមមេដៃរបស់អ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី។

- រាល់ព័ត៌មានដែលអាចរកបាន ពាក់ព័ន្ធនឹងឧក្រិដ្ឋកម្មមួយ ឬច្រើន ដូចដែលបានចោទដោយអ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី (តុលាការចាំបាច់ត្រូវកំណត់ថា អ្វីដែលបានកើតឡើងចំពោះអ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីគឺ ពាក់ព័ន្ធនឹងឧក្រិដ្ឋកម្មនានា ដែលកំពុងត្រូវបានស៊ើបអង្កេតដោយតុលាការ)។ ការពណ៌នាអំពីឧក្រិដ្ឋកម្មគួរបញ្ជាក់ឲ្យបានច្បាស់ និងមានលក្ខណៈសមស្របពាក់ព័ន្ធនឹងទីតាំង (រួមមានឈ្មោះទីកន្លែងដែលឧក្រិដ្ឋកម្មបានកើតឡើង និងយ៉ាងហោចណាស់ ឈ្មោះស្រុក និងខេត្តនៃទីកន្លែងនោះ) និងឆ្នាំ ដែលឧក្រិដ្ឋកម្មនោះបានកើតឡើង។
- **ភស្តុតាងអត្តសញ្ញាណ**នៃបុគ្គល ដែលដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី។ នេះអាចជាសំណៅថតចម្លងនៃអត្តសញ្ញាណប័ណ្ណ ឬសៀវភៅគ្រួសារ ឬលិខិតចេញដោយអាជ្ញាធរឃុំ/សង្កាត់ ឬអាជ្ញាធរខ្ពស់ជាងហ្នឹង។ បើអាចធ្វើបាន លិខិតនោះគួរត្រូវបានបោះត្រាត្រឹមត្រូវ។
- រាល់ឯកសារគាំទ្រដល់ព័ត៌មានដែលផ្តល់ដោយអ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី ប្រសិនបើអាចរកបាន ។ ឧទាហរណ៍ រូបថតជនរងគ្រោះជាដើម។
- បើត្រូវការសេចក្តីណែនាំលម្អិតអំពីរបៀបបំពេញទំរង់បែបបទព័ត៌មានជនរងគ្រោះ សូមទាក់ទងជាមួយអង្គភាពជនរងគ្រោះ (តាមព័ត៌មានខាងក្រោមនេះ)។

6. ចំពោះអ្នកដែលមិនប្រាថ្នាចង់ចូលរួមក្នុងនាមជាដើមបណ្តឹងរដ្ឋប្បវេណីទេនោះ ក៏នៅតែអាចដាក់ពាក្យបណ្តឹងបាន ដោយភ្ជាប់មកជាមួយនូវព័ត៌មាន និង/ឬភស្តុតាងដែលមានប្រយោជន៍ ពាក់ព័ន្ធនឹងឧក្រិដ្ឋកម្មដែលបានប្រព្រឹត្តដោយខ្មែរក្រហម។ ភស្តុតាងទាំងនេះនឹងត្រូវបានពិចារណាដោយសហព្រះរាជអាជ្ញា ហើយបើសមស្រប ពួកគេនឹងប្រើឆន្ទានុសិទ្ធិដើម្បីសម្រេចថា តើត្រូវច្រានចោលពាក្យបណ្តឹងនោះ, បញ្ចូលពាក្យបណ្តឹងនោះទៅក្នុងការស៊ើបអង្កេតដែលកំពុងដំណើរការ, រៀបចំការស៊ើបអង្កេតថ្មីមួយទៀត ឬបញ្ជូនពាក្យបណ្តឹងនោះទៅសហចៅក្រមស៊ើបអង្កេតតែម្តង ដើម្បីប្រើក្នុងការស៊ើបអង្កេត ដែលកំពុងដំណើរការ។ អ្នកដាក់ពាក្យបណ្តឹងអាចត្រូវបានសហព្រះរាជអាជ្ញាកោះអញ្ជើញមកធ្វើជាសាក្សី ។ ការដាក់ពាក្យបណ្តឹងនេះមិនមានពេលកំណត់ទេ ។ ទោះជាយ៉ាងនេះក្តី ព័ត៌មាននេះគួរផ្តល់ឲ្យបានឆាប់បំផុតតាមតែអាចធ្វើបាន ដើម្បីជាប្រយោជន៍បង្កើនលទ្ធភាពសម្រាប់ការិយាល័យសហព្រះរាជអាជ្ញាធ្វើការពិចារណាលើព័ត៌មានរបស់លោកអ្នក។

7. ចំពោះអ្នកដែលចង់ក្លាយខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី ឬចង់ដាក់ពាក្យបណ្តឹង គួរបំពេញទំរង់បែបបទព័ត៌មានជនរងគ្រោះ។ ទំរង់បែបបទនេះមាននៅអង្គភាពជនរងគ្រោះ និងនៅលើគេហទំព័ររបស់អ.វ.ត.ក ដែលមានជាភាសាខ្មែរ, អង់គ្លេស និងបារាំង។ ក្នុងនោះក៏មានគោលការណ៍ណែនាំ ដើម្បីពន្យល់អំពីខ្លឹមសារទំរង់បែបបទនេះដោយពិស្តារដែរ។ ទំរង់បែបបទ និងគោលការណ៍ណែនាំនេះគឺអាចរកបានដោយឥតគិតថ្លៃ ហើយការដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី និង/ឬ ការដាក់ពាក្យបណ្តឹងនានាមិនចាំបាច់

ចំណាយប្រាក់កាសឡើយ។

8. ក្រោយពីបំពេញរួច សូមយកទំរង់បែបបទនេះទៅដាក់នៅអង្គភាពជនរងគ្រោះ។ បើត្រូវការទំរង់បែបបទ និងគោលការណ៍ណែនាំ និងមតិយោបល់បន្ថែម សូមទាក់ទងទៅអង្គភាពជនរងគ្រោះតាមរយៈ៖

- ទូរស័ព្ទលេខ៖ 012 842 861 ឬ 097 742 4218
- ឬអញ្ជើញទៅមជ្ឈមណ្ឌលព័ត៌មានតាមអាស័យដ្ឋានខាងក្រោម៖

**អង្គភាពជនរងគ្រោះ** (មជ្ឈមណ្ឌលព័ត៌មាន)

ផ្ទះលេខ៦A ផ្លូវ២១ សង្កាត់ទន្លេបាសាក់ I

ខណ្ឌចំការមន ភ្នំពេញ កម្ពុជា

- សារអេឡិចត្រូនិច: victimsunit@eccc.gov.kh

អង្គភាពជនរងគ្រោះត្រៀមខ្លួនចាំជួយលោកអ្នក ដែលចង់បំពេញទំរង់បែបបទព័ត៌មានជនរងគ្រោះ។ ការិយាល័យយើងខ្ញុំចាប់បើកពីម៉ោង០៨:០០ព្រឹក រហូតដល់ម៉ោង ០៥:០០ ល្ងាច ពីថ្ងៃច័ន្ទដល់ថ្ងៃសុក្រ លើកលែងតែថ្ងៃឈប់សម្រាក។

**ការដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណី ឬដាក់ពាក្យបណ្ដឹង មិនមានចំណាយអ្វីទាំងអស់**